ដូចកូនប្រុសរបស់ខ្ញុំដែរ។ ក្នុងការបន្តនិយាយពីរឿងទាក់ទងនឹងខែជាប្រវត្តិសាស្ត្ររបស់ស្ត្រី ខ្ញុំចង់និយាយអំពីស្ត្រីម្នាក់ដែលធ្វើការមិនខ្លាចនឿយហត់ ដើម្បីធ្វើអោយអនាគតនៃស្ត្រី និងកុមារី ដែលប្រឈមនឹងគ្រោះថ្នាក់ មានភាពប្រសើរឡើង គឺលោកស្រី ប៉ុក បញ្ញាវិចិត្រ ដែលជានាយកប្រតិបត្តិនៃមជ្ឈមណ្ឌលស្ត្រីមានវិបត្តិកម្ពុជា (CWCC) ។ លោកស្រី បញ្ញាវិចិត្របានកើតនៅខេត្តកណ្តាល ហើយបានសិក្សានៅភ្នំពេញ។ អស់រយៈពេលជាច្រើនឆ្នាំហើយដែលលោកស្រីបានតស៊ូមតិដើម្បីសិទ្ធិរបស់ស្ត្រី និងកុមារី ដោយបានធ្វើការអោយរដ្ឋាភិបាលកម្ពុជា ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ និងសង្គមស៊ីវិលក្នុងស្រុក។

មជ្ឈមណ្ឌល CWCC ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៧ ជួយអ្នករួចពីអំពើហឹង្សាក្នុងគ្រួសារ ការរំលោភផ្លូវភេទ និងការជួញដូរមនុស្ស បានស្បៀយពីការឈឺចាប់ និងហឹង្សាដែលគេបានទទួល។ ខ្ញុំជឿថា ជោគជ័យរបស់ CWCC នៅក្នុងការធានាការការពារសិទ្ធិរបស់ស្ត្រីត្រូវបានបញ្ជាក់ជាសង្ខេបដោយបាវចនារបស់គេថា “ជួយស្ត្រីអោយជួយខ្លួនគេ” ។ មុខងារមួយក្នុងចំណោមមុខងារស្នូលរបស់មជ្ឈមណ្ឌល CWCC គឺផ្តល់អោយស្ត្រី និងកុមារនូវទីជំរក និងការគាំពារនៅតាមកន្លែងអោយស្នាក់នៅមួយក្នុងចំណោមកន្លែងអោយស្នាក់នៅចំនួន ៣របស់គេនៅភ្នំពេញ សៀមរាប និងបន្ទាយមានជ័យ។
ទីជំរកទាំងនោះមិនគ្រាន់តែផ្តល់ការស្នាក់អាស្រ័យបណ្តោះអាសន្នប្រកបដោយសុវត្ថិភាព សំរាប់ស្ត្រី និងកុមារដែកគេចចេញពីអំពើហឹង្សាតែប៉ុណ្ណោះទេ តែវាថែមទាំងផ្តល់អោយពួកគេផងដែរនូវការថែទាំជំងឺ និងការប្រឹក្សា ការការពារតាមផ្លូវច្បាប់ អក្ខរកម្ម និងការបង្រៀនជំនាញវិជ្ជាជីវៈ និងការរៀនពីរបៀបវិលទៅរស់នៅកន្លែងដើមរបស់គេវិញថែមទៀតផង។



– មជ្ឈមណ្ឌល CWCC ផ្តល់អោយស្ត្រី និងកុមារនូវទីជំរក និងការគាំពារនៅតាមកន្លែងអោយស្នាក់នៅ នៅភ្នំពេញ សៀមរាប និងបន្ទាយមានជ័យ(រូបថតរបស់មជ្ឈមណ្ឌល CWCC) ។

ផ្នែកមួយទៀតនៃការឆ្លើយតបរបស់មជ្ឈមណ្ឌល CWCC ចំពោះអំពើហឹង្សាទៅលើស្ត្រីគឺកម្មវិធីផ្តល់ជំនួយផ្នែកច្បាប់របស់គេ ដែលមានបំណងធ្វើអោយស្ត្រីអាចចាកផុតពីស្ថានភាពធ្វើបាប ឬកេងប្រវ័ញ្ច ហើយផ្តល់អោយស្ត្រីទាំងនេះនូវការណែនាំនិងការគាំទ្រផ្នែកច្បាប់ ដើម្បីចាប់អោយអ្នកប្រព្រឹត្តទទួលខុសត្រូវចំពោះសកម្មភាពហឹង្សានិងបទល្មើសរបស់គេ។ សេវានេះមានសារៈសំខាន់ណាស់ ពីព្រោះស្ត្រីជាច្រើនក្រគ្មានប្រាក់រកមេធាវីមកអោយធ្វើជាតំណាងអោយពួកគេទេ។



– មជ្ឈមណ្ឌល CWCC ជឿថា
គ្រប់ស្ត្រីទាំងអស់មានសិទ្ធិក្នុងការទទួលបានការណែនាំ
និងការគាំពារផ្លូវច្បាប់
បើគាត់ចង់ស្វែងរកការដោះស្រាយនៅក្នុងតុលាការ(រូបថតរបស់មជ្ឈមណ្ឌល
CWCC) ។

ការជួញដូរមនុស្សគឺជាកង្វល់មួយដែលមានកាន់តែច្រើនឡើងនៅកម្ពុជា ហើយមជ្ឈមណ្ឌល CWCC កំពុងជួយស្ត្រីនិងកុមារីអោយវិលត្រឡប់ទៅផ្ទះ និងសហគមន៍របស់គេវិញ។ អង្គការនេះបានបង្កើតកម្មវិធីមួយដើម្បីកាត់បន្ថយការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព ដោយធ្វើយុទ្ធនាការលើកកំពស់ការយល់ដឹងលើការជួញដូរមនុស្ស។



– មជ្ឈមណ្ឌល CWCC
ជួយស្ត្រីនិងកុមារដែលត្រូវបានជួញដូរទៅប្រទេសដទៃ(រូបថតរបស់មជ្ឈមណ្ឌល
CWCC)។

អស់រយៈពេលរាប់ឆ្នាំមកហើយដែលមជ្ឈមណ្ឌល CWCC បានឈានមុខគេនៅក្នុងការផ្លាស់ប្តូរឥរិយាបទរបស់មនុស្សលើហឹង្សាលើស្ត្រី។ គេបានធ្វើជាដៃគូជាមួយមន្ត្រីរដ្ឋាភិបាល ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីនគរបាល និងអាជ្ញាធរមូលដ្ឋាន ដើម្បីជួយអោយគេក្តាប់បាន និងពង្រឹងការអនុវត្តច្បាប់ដែលការពារសិទ្ធិរបស់ស្ត្រី និងកុមារនៅតាមសហគមន៍ជនបទ ទូទាំងប្រទេស។ នៅក្នុងរយៈពេលបំពេញការងារជិត ២ ទសវត្ស មជ្ឈមណ្ឌល CWCC បានជួយមនុស្សចំនួនជិត ២០ ០០០

នាក់អោយគេចចេញពីការឈឺចាប់ ហើយកសាងជីវិតរបស់គេឡើងវិញ។
ខ្ញុំសូមអរគុណលោកស្រីបញ្ញាវិចិត្រចំពោះការដឹកនាំដ៏ប្រពៃរបស់គាត់នៅក្នុងមជ្ឈមណ្ឌល CWCC និងការប្តេជ្ញាចិត្តរបស់គាត់ក្នុងការផ្តល់លទ្ធភាពដល់ជនរងគ្រោះដោយអំពើហឹង្សា និងការជួញដូរមនុស្សនៅកម្ពុជា នៅក្នុងការកសាងជីវិតរបស់គេ និងជីវិតនៃកូនរបស់គេ។




– លោកស្រី ប៉ុក បញ្ញាវិចិត្រទទួលបានប័ណ្ណស្តីពីគំរោងការប្រតិបត្តិល្អក្នុងអង្គការមិនមែនរដ្ឋាភិបាល(រូបថតរបស់មជ្ឈមណ្ឌល CWCC)។

This entry was posted in **Uncategorized** and tagged **Trafficking**, **Women** by **Ambassador Todd**. Bookmark the

.